THE SCHOOL DISTRICT OF PHILADELPHIA

**ការិយាល័យអគ្គនាយកក្រសួងអប់រំ**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២៣

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ឆ្នាំសិក្សា ២០២២-២០២៣ ជិតចប់ហើយ ហើយដូចគ្នានឹងលោកអ្នកដែរ យើងមើលទៅកាន់រដូវក្តៅ។ ទោះបីជាការិយាល័យសុខភាពសិស្សនឹងមិនមានទំនាក់ទំនងផ្ទាល់ និងជាប់លាប់ជាមួយសិស្សដែលយើងមានក្នុងអំឡុងឆ្នាំសិក្សាក៏ដោយ ក៏យើងសុំឱ្យលោកអ្នកប្រើប្រាស់ធនធាន ព្រឹត្តិការណ៍ និងការផ្តើមគំនិតជាច្រើនដែលបានរៀបចំឡើងដើម្បីគាំទ្រដល់សុខភាពផ្លូវចិត្ត និងរាងកាយ ក្នុងរដូវក្តៅនេះ។

**<u>ការចាក់ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយ ដោយផ្ទាល់</u>**

ក្រសួងអប់រំបានសហការជាមួយអង្គការមួយចំនួនដើម្បីធានាថាសិស្សានុសិស្ស ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី ១២ ទាំងអស់ នឹងមានភាពងាយស្រួលក្នុងការទទួលការពិនិត្យរាងកាយ និងការចាក់ថ្នាំបង្ការរោគដែលពួកគេត្រូវការដើម្បីត្រឡប់ទៅសាលារៀនវិញនៅរដូវស្លឹកឈើជ្រុះនេះ។ តាមរយៈនៃការសហការរបស់យើងជាមួយ CityLife Health និង Delaware Valley Community Health ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយ នឹងផ្តល់ឱ្យសិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) នៅទីតាំងដែលបានជ្រើសរើសមួយចំនួន ក្នុងខែ កក្កដា និង សីហា។ នៅខែ សីហា ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយ នឹងផ្តល់ឱ្យសិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា នៅក្នុង ព្រឹត្តិការណ៍ធំៗមួយចំនួនតាមរថយន្តសាលាដែលឆ្លងកាត់តំបន់ដែលសិស្សរស់នៅ ក្នុងឆ្នាំ ២០២៣ (2023 Back-to-School Bus Tour Mega-Events)។ លើសពីនេះ សិស្សានុសិស្សទាំងអស់ ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី ១២ អាចទទួលថ្នាំបង្ការរោគ ឬការពិនិត្យរាងកាយរបស់ពួកគេនៅ CityLife Health Clinic ឬ City Health Center (មជ្ឈមណ្ឌលសុខភាពរបស់ទីក្រុង) ក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា ព្រមទាំងពីក្រុមផ្តល់សេវាថែទាំសុខភាពរបស់ពួកគេផងដែរ។ សេវាកម្មទាំងនេះនឹងផ្តល់ឱ្យសិស្សទាំងអស់ ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី ១២ ដោយមិនគិតពីស្ថានភាពនៃការធានារ៉ាប់រង។ សិស្សដែលមានអាយុក្រោម ១៨ ឆ្នាំ ត្រូវតែមានការយល់ព្រមតាមរយៈនៃក្រដាសស្នាម ឬតាមទូរស័ព្ទ។ គេចង់បានការណាត់ជួបទុកជាមុន។ ដើម្បីស្វែងរកទីតាំង ឬណាត់ពេលជួប សូមចូលទៅកាន់គេហទំព័រ www.philasd.org/vax។

**<u>សហគមន៍សុខុមាលភាពផ្លូវចិត្តតាមរយៈអនឡាញ (Kooth Online Mental Wellbeing Community)</u>**

សិស្សវិទ្យាល័យរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ារាប់រយនាក់ បានប្រើ Kooth ដែលជាសហគមន៍សុខភាពផ្លូវចិត្ត និងសុខុមាលភាព តាមរយៈអនឡាញ ដែលមានសុវត្ថិភាព និងជាសម្ងាត់ ដែលបានចាប់ផ្តើមនៅឆ្នាំ

នេះ។ ពួកគេបានចូលប្រើ ការប្រឹក្សាពីអ្នកជំនាញ ការគាំទ្រពីមិត្តភ័ក្តិ និងឧបករណ៍សម្រាប់ជួយខ្លួនឯង ដូចជាធនធានក្នុងការកំណត់គោលដៅ ដំបូន្មាន និងមតិផ្តោត និងបទពិសោធន៍ផ្ទាល់ខ្លួនដែលបានសរសេរ ពីមិត្តភ័ក្តិ និងអ្នកជំនាញ។ Kooth នឹងទស្សនា ព្រឹត្តិការណ៍ធំៗមួយចំនួនតាមរថយន្តសាលាដែលឆ្លងកាត់តំបន់ដែលសិស្សរស់នៅ ក្នុងឆ្នាំ ២០២៣ ដើម្បីជួយផ្សព្វផ្សាយអំពី Kooth ឱ្យសិស្សចុះឈ្មោះចូលរួម និងចែករំលែកពីរបៀបដែលសិស្សអាចចូលរួមក្នុងការឃោសនាបញ្ចុះបញ្ចូល សុខមាលភាពក្នុងរដូវក្តៅ (#SummerWellness) របស់ពួកគេ និងប្រកួតប្រជែងដើម្បីឱកាសឱ្យកីឡាករបាល់អោប Philadelphia Eagle និង ជាតំណាងរបស់ Kooth ឈ្មោះ Lane Johnson ធ្វើទស្សនកិច្ចនៅសាលារបស់ពួកគេនៅរដូវស្លឹកឈើជ្រុះនេះ។ យើងសង្ឃឹមថាលោកអ្នកនឹងមកកាន់តុរបស់ Kooth នៅក្នុងព្រឹត្តិ ការណ៍ដ៏ធំ (Mega-Events) នារដូវក្តៅនេះ ដើម្បីស្វែងយល់បន្ថែមអំពីធនធានដ៏សំខាន់នេះ ដែលជួយសិស្សឱ្យមានអារម្មណ៍ថាមានទំនាក់ទំនង មានការទទួលយក និងមានការយល់ដឹង។

**<u>ការធានារ៉ាប់រងសុខភាព និងធនធានសំបុត្រពេទ្យរដ្ឋ (Health Insurance & Medicaid Resources)</u>**

នរណាម្នាក់ដែលទទួលការធានារ៉ាប់រងសុខភាពពីរដ្ឋត្រូវតែសុំបន្តការធានារ៉ាប់រងសម្រាប់ Medicaid, Medical Assistance ឬ CHIP របស់ពួកគេជារៀងរាល់ឆ្នាំ។ នៅរដូវផ្ការីកនេះ ក្រសួងអប់រំបានរៀបចំវេទិកាផ្តល់ព័ត៌មាន និងការណែនាំសម្រាប់ការទទួល និងសុំបន្តការធានារ៉ាប់រងសុខភាព។ លោកអ្នកអាចមើលវេទិកា <u>នៅទីនេះ</u>។ សម្រាប់ជំនួយបន្ថែមក្នុងការចុះឈ្មោះ ឬសុំបន្តការធានារ៉ាប់រងសុខភាព សូមហៅទូរស័ព្ទ ឬផ្ញើសារតាមទូរស័ព្ទដៃទៅកាន់ បណ្តាញទទួលការធានារ៉ាប់រងសុខភាពរដ្ឋផិនស៊ីលវេនញ៉ា (Pennsylvania Health Access Network) តាមរយៈលេខ (877) 570-3642 ឬបំពេញ <u>លិខិតសុំជំនួយ</u> <u>Get Help Form</u> នេះ។

នៅតែប៉ុន្មានថ្ងៃទៀតយើងនឹងដល់ថ្ងៃចេញផ្សាយផែនការយុទ្ធសាស្រ្តថ្មីរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ទោះជាខ្ញុំនឹងមិនផ្តល់ព័ត៌មានទាំងអស់នៅពេលនេះ ខ្ញុំអាចនិយាយបានថា ការគាំទ្រដល់សុខភាពផ្លូវកាយ និងការយល់ដឹងពីសង្គមរបស់សិស្សយើងគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពកំពូលនៅក្នុងផែនការនេះ។ ការផ្តួចផ្តើមគំនិតអំពីសុខភាពផ្លូវចិត្ត និងផ្លូវកាយនារដូវក្តៅនេះគឺជាសកម្មភាពដែលធ្វើឡើងដោយចេតនាក្នុងការអនុលោមតាមអាទិភាពនោះ។

ខ្ញុំសូមជូនពរលោកអ្នកឱ្យមានរដូវក្តៅដ៏អស្ចារ្យ! ក្នុងភាពជាដៃគូ។

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា